# គម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ( RIA ) នៅកម្ពុជា

## ហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## លេខ 0224-CAM ( SF )

ដោយ

**យឹម ណុលសន**

**អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**និង ជានាយកគម្រោង RIA**

ឧសភា ២០១៩

# មាតិកា

- ហេតុអ្វីបានត្រូវការ RIA ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត?
- សាវតានៃគម្រោង RIA នៅកម្ពុជា
- គោលដៅនៃគម្រោង RIA នៅកម្ពុជា
- រចនាសម្ព័ន្ធនៃគម្រោង RIA នៅកម្ពុជា
- គោលការណ៍សំខាន់ ក្នុងការអនុវត្ត RIA នៅកម្ពុជា
- ២ តំណាក់កាល នៃការអនុវត្ត RIA នៅកម្ពុជា
- ចំណុចទាំង ៧ នៃ RIA នៅកម្ពុជា
- នីតិវិធីអនុម័តលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា
- ការរៀបចំ របាយការណ៍ PA ឬរបាយការណ៍ RIS
- លទ្ធផលសម្រេចបាន
- ការប្រឈម

# ហេតុអ្វីបានត្រូវការ RIA ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត?

- លិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងឡើងដោយមានការប្រុងប្រយ័ត្ន ដើម្បីចៀសវាងកុំឲ្យមានផលប៉ះពាល់ដែលមិនបានស្មានទុក ឬផលអវិជ្ជមានផ្សេងៗ ដូចជាការរឹតបន្តឹងការប្រកួតប្រជែង ឬការដាក់បន្ទុកចំណាយដ៏ធ្ងន់ធ្ងរដែលមិនចាំបាច់ទៅលើអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ដោយសារបទប្បញ្ញត្តិទាំងនោះ។
- រដ្ឋាភិបាលត្រូវធ្វើការវាយតម្លៃដោយប្រយ័ត្នប្រយែងពីបន្ទុក និងផលប្រយោជន៍នៃការដាក់បញ្ចូលបញ្ញត្តិកម្មថ្មី។
- RIAត្រូវបានប្រទេសជឿនលឿនជាច្រើននៃ EU និង OECD អនុវត្តសម្រាប់ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តឲ្យប្រសើរឡើង មានប្រសិទ្ធភាពនិងប្រសិទ្ធិផលខ្ពស់ សូម្បីប្រទេសវៀតណាមក៏ចាប់អនុវត្តតាំងពីឆ្នាំ២០០៩មកដែរ តែតាមរូបភាពនិងទម្រង់ខុសៗគ្នា ដូចប្រទេសអូស្ត្រាលី ប្រទេសអង់គ្លេស វៀតណាម។
- ប្រទេសកម្ពុជាពុំមានបញ្ញត្តិកំណត់ពេលបញ្ចប់សុពលភាពនៃបទប្បញ្ញត្តិ (sunset clause) ហើយក៏ពុំមានយន្តការវាយតម្លៃវិសាលភាពជាន់គ្នានៃបទប្បញ្ញត្តិទាំងនោះដែរ។
- នីតិវិធីអនិវត្ត RIA នឹងធ្វើឲ្យអភិបាលកិច្ចប្រសើរឡើង ដែលជាចំណុចស្នូលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាល ដែលបានដាក់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច ការងារនិងប្រសិទ្ធភាព។